ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះជាម្ចាស់សាកចិត្តលោកអប្រាហាំ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Tammy S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។



នៅយប់មួយនោះ ព្រះជាម្ចាស់បាន
មានព្រះបន្ទូលយ៉ាងម៉ឺងម៉ាត់ទៅ
លោកអប្រាហាំ។
សេចក្ដីបង្គាប់នោះ
ជាការសាកចិត្ត ថាតើលោក
អាប្រាហាំស្រឡាញ់អ៊ី
សាក់ជាកូន ខ្លាំងជាង
ឬមួយលោក
ស្រឡាញ់ព្រះជាម្ចាស់ខ្លាំងជាង។

ព្រះជាម្ចាស់បានបង្គាប់ថា ៖ “ចូរយកអ៊ីសាក់ជាកូនរបស់អ្នក ទៅថ្វាយជាតង្វាយដុត”។ ថ្វាយ អ៊ីសាក់? យកកូនប្រុសរបស់លោកធ្វើជាតង្វាយដុត? ការនោះពិតជាលំបាកខ្លាំងណាស់ចំពោះលោកអប្រាហាំ។ លោកស្រឡាញ់ កូនប្រុសរបស់លោកខ្លាំងណាស់។



ប៉ុន្តែលោកអប្រាហាំ បានរៀនពីការទុកចិត្តលើព្រះជា
ម្ចាស់ ទោះបីជាក្នុងគ្រាដែលលោកមិនទាន់យល់
ច្បាស់ក៏ដោយ។ ព្រឹកឡើង លោកបាន
រៀបចំអុសសម្រាប់ថ្វាយតង្វាយដុត
ហើយចេញដំណើរ ទៅភ្នំមួយ ជាមួយអ៊ីសាក់
និង អ្នកបម្រើពីរនាក់។



មុនពេលចេញដំណើរ, លោកអប្រាហាំបានរៀបចំអុសសម្រាប់ដុត
តង្វាយដុត។ លោកបានសម្រេចចិត្ត
ថានឹងស្ដាប់បង្គាប់ព្រះជាម្ចាស់។





បីថ្ងៃក្រោយមក
ពួកលោកក៏បានមកកៀកនឹងភ្នំដែល
លោកត្រូវថ្វាយតង្វាយដុត។ លោកមានប្រសាសន៍ទៅ
កាន់អ្នកបម្រើទាំងពីរនាក់ថា ៖ “សូមចាំនៅទីនេះ
ហើយ យើងនឹងឡើងទៅថ្វាយបង្គំព្រះជាម្ចាស់នៅលើភ្នំ
រួចហើយយើងនឹងត្រឡប់មករកអ្នកវិញ”។
អ៊ីសាក់ លីអុសនៅលើស្មា
ឯលោកអប្រហាំលោកកាន់
ភ្លើង និង កាំបិត។

អ៊ីសាក់ សួរលោកអប្រាហាំជាឪពុកថា
“ពុក! តើកូនចៀមសម្រាប់ថ្វាយតង្វាយ
ដុត នៅណា?” លោកអប្រាហាំឆ្លើយថា
៖ “ព្រះជាម្ចាស់ផ្ទាល់ នឹងផ្គត់ផ្គង់កូន
ចៀមមកយើងណាកូន”។



អ្នកទាំងពីរបានដើរមកដល់កន្លែងមួយដែលព្រះជាម្ចាស់បានជ្រើសរើ
ស។ នៅកន្លែងនោះ លោកអប្រាហាំបានសង់អាសនាមួយ
ហើយលោករៀបចំអុសដើម្បីដុតតង្វាយ នៅ
ចំពោះព្រះជាម្ចាស់។ លោកអប្រាហាំ
ធ្លាប់បានសង់អាសនាជាច្រើនមកហើយ។
ប៉ុន្តែអាសនាមួយនេះ ជាអាសនាដែល
ពិបាកសង់ជាគេបំផុត។



លោកអប្រាហាំ ចងអ៊ីសាក់ ហើយយកកូនប្រុសដ៏ជាទីស្រឡាញ់របស់លោកទៅដាក់លើអាសនា។ តើលោកអប្រាហាំ ពិតជានឹងស្ដាប់បង្គាប់ព្រះជាម្ចាស់ ហើយពិតជានឹងថ្វាយអ៊ីសាក់ ជាកូនប្រុសតែម្នាក់គត់របស់លោក ជាតង្វាយដុតមែនទេ?





ពិតមែនហើយ!
លោកអប្រាហាបានលើកកំបិត
ឡើងយ៉ាងខ្ពស់។ ចិត្តរបស់លោកពោរ
ពេញដោយការឈឺចាប់យ៉ាងខ្លាំង
ប៉ុន្តែលោកអប្រាហាំដឹងច្បាស់ថា
លោកត្រូវតែស្តាប់បង្គាប់ព្រះជាម្ចាស់។



ទេវតានៃព្រះអ
ម្ចាស់បានស្រែក
បង្គាប់ពីលើមេឃមក
ថា ៖ “ឈប់ភ្លាម! ឥឡូវនេះ
យើងដឹងថា អ្នកពិតជា
កោតខ្លាចព្រះជាម្ចាស់
ប្រាកដមែន។ អ្នកមិន
បានទុកសូម្បីតែកូន
ប្រុសតែមួយដ៏ជាទី
ស្រឡាញ់របស់
អ្នក”។



លោកអប្រាហាំបានស្រាយអ៊ីសាក់ពីចំណងវិញ ហើយលោកបានយកចៀមឈ្មោលមួយក្បាល ដែលបានជាប់ស្នែងនឹងគុម្ពោតព្រៃ មកថ្វាយជាតង្វាយដុតជំនួសវិញ។ ប្រហែលជាអ៊ីសាក់ក៏បាន គិតក្នុងចិត្តដែរថា៖ “ព្រះជាម្ចាស់នឹងផ្គត់ផ្គង់ដូចឪពុករបស់លោកបានមានប្រសាសន៍មែន”។

ក្នុងពេលដែលឪពុក និង កូនបានថ្វាយបង្គំព្រះជាម្ចាស់នោះ ទេវតានៃព្រះអម្ចាស់បាននិយាយទៅ កាន់លោកអប្រាហាំថា ៖ “ប្រជាជាតិនានា នឹងបានទទួលព្រះពរតាមរយៈពូជពង្សរបស់អ្នក”។ ថ្ងៃមួយ ព្រះយេស៊ូ នឹងប្រសូតមកតាមរយៈពូជពង្សលោកអប្រាហាំ។



លោកអប្រាហាំ និង អ៊ីសាក់ជាកូន ក៏បានវិលត្រឡប់ទៅផ្ទះវិញ។
មួយរយៈក្រោយមកទៀត មានរឿងដ៏ក្រៀមក្រំមួយបានចូលមកទៀត។
លោកស្រីសារ៉ា បានទទួលមរណៈភាព។
លោកអប្រាហាំ បានបាត់បង់ភរិយារបស់លោក ឯអ៊ីសាក់
បានបាត់បង់ម្តាយរបស់ខ្លួន។




ក្រោយពីរៀបចំទុកដាក់សព
រួចរាល់ហើយ
លោកអប្រាហាំបាន
ចាត់តាំងបុរសម្នាក់ដែលជាមេលើ
ពួកអ្នកបម្រើរបស់លោកឲ្យចេញទៅរកភរិយាម្នាក់
មកឲ្យអ៊ីសាក់។

អ្នកបម្រើនោះបានទៅដល់ភូមិ
កំណើតរបស់លោកអប្រាហាំ
ហើយរកបាននារីម្នាក់ពីក្នុង
ចំណោមសាច់ញ្ញាតិរបស់លោក។



អ្នកបម្រើនោះបានទូលសុំទីសម្គាល់មួយពីព្រះជាម្ចាស់ថា ៖ “សូមឲ្យនារីដែលដងទឹកមកឲ្យសត្វអូដ្ឋ របស់ទូលបង្គំផឹក ត្រូវចំនារីដែលព្រះអង្គប្រទានជាភរិយារបស់អ៊ីសាក់”។ រំពេចនោះ នាងរ៉េបេកា បានមកហើយដងទឹកឲ្យសត្វអូដ្ឋទាំងអស់របស់លោកផឹកមែន។ នាងជានារីម្នាក់ក្នុងចំណោម សាច់ញាតិរបស់លោកអប្រាហាំ។ អ្នកបម្រើនោះដឹងជាក់ក្នុងចិត្តថា គឺព្រះជាម្ចាស់បានឆ្លើយតប ចំពោះការអធិស្ឋានរបស់លោកមែន។



នាងរេបេកាបានចាកចេញពីគ្រួសារ ទៅរៀបការជាមួយអ៊ីសាក់។ នាង
ធ្វើឲ្យលោកអ៊ីសាក់បាន ស្រាកពីទុក្ខសោកនៃមរណៈភាពរបស់ម្ដាយ។
លោកអ៊ីសាក់ស្រឡាញ់នាងខ្លាំងណាស់!



ព្រះជាម្ចាស់សាកចិត្តលោកអប្រាហាំ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ២២-២៤

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាមែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣៖១៦